ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ: ៦៥២ ..... សហវ.ប្រក

ភ្នំពេញ ថ្ងៃទី១៩ ខែមេសា ឆ្នាំ ២០១២

# ប្រកាស
## ស្តីពី
## ការតែងតាំងមន្ត្រីអង្គភាពគ្រប់គ្រង និងសម្របសម្រួល ការអនុវត្តគម្រោងមូលនិធិធានាឥណទាន (អ.ម.ធ.ឥ.)

## ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែល ប្រកាសឱ្យ ប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១០/០១៧ ចុះថ្ងៃទី ១២ ខែ ឧសភា ឆ្នាំ ២០០៨ ដែល ប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១០/០១៧ ចុះថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ២០១០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១១
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៦ អនក្រ.បក ចុះថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០០៣ ស្តីពីការបង្កើត នាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាននៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ និង អនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០០៨ ស្តីពីការបំពេញបន្ថែម និងកែសម្រួលនាយកដ្ឋានមួយចំនួននៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

- បានឃើញអនុក្រឹត្យលេខ ១៣៤ អនក្រ.បក ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការដំឡើងទីចាត់ការគយ និងរដ្ឋាករ នាយកដ្ឋានពន្ធដារ និងរតនាគារជាតិនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ឱ្យ ទៅជាអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញឯកសារគោនយោបាយស្តីពីការជម្រុញផលិតកម្មស្រូវ និងការនាំចេញអង្ករ របស់រាជ-រដ្ឋាភិបាល ដែលអនុម័តដោយទីស្តីការគណៈរដ្ឋមន្ត្រី នៅថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០១០
- បានឃើញប្រកាសលេខ ១០៤០ សហវ.ប្រក ចុះថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១១ របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ស្តីពីការបង្កើតអង្គភាពគ្រប់គ្រង និងសម្របសម្រួលការអនុវត្តគម្រោងមូលនិធិធានាឥណទាន
- បានឃើញប្រកាសលេខ ១៣៥ សហវ.ប្រក ចុះថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០១២ របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃអង្គភាពគ្រប់គ្រង និងសម្របសម្រួលការអនុវត្តគម្រោងមូលនិធិធានាឥណទាន (អ.ម.ធ.ឥ.)
- តាមការចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## សម្រេច

**ប្រការ១:** ត្រូវបានតែងតាំងមន្ត្រីអង្គភាពគ្រប់គ្រង និងសម្របសម្រួលការអនុវត្តគម្រោងមូលនិធិធានាឥណទាន ដូចមានរាយនាមខាងក្រោម៖

ថ្នាក់គ្រប់គ្រង

| | |
|---|---|
| ១- លោក **សំ ថនរី** | នាយកប្រតិបត្តិរង |

ផ្នែកប្រតិបត្តិការ

| | |
|---|---|
| ២- លោក **ឱម ម៉ាក់ធារិទ្ធ** | ប្រធានផ្នែកប្រតិបត្តិការ |
| ៣- លោក **សៀង ចំណាន** | អនុប្រធានផ្នែកប្រតិបត្តិការ |
| ៤- លោក **មាស សំអាន** | មន្ត្រីផ្នែកប្រតិបត្តិការ |
| ៥- លោក **ចាន់ សុបញ្ញាច័ន** | មន្ត្រីផ្នែកប្រតិបត្តិការ |
| ៦- កញ្ញា **ម៉ាត់ សៅវលក្ខណ៍** | មន្ត្រីផ្នែកប្រតិបត្តិការ |

ផ្នែកកិច្ចការច្បាប់

| | |
|---|---|
| ៧- លោក **ហ៊ែល ចំរើន** | ប្រធានផ្នែកកិច្ចការច្បាប់ |
| ៨- លោក **ស៊ាង ផល្លា** | មន្ត្រីផ្នែកកិច្ចការច្បាប់ |

ផ្នែកព័ត៌មានវិទ្យា

| | |
|---|---|
| ៩- លោក **ទេព តិយ៉ោរិទ្ធ** | ប្រធានផ្នែកព័ត៌មានវិទ្យា |



12

១០- លោក **នៅ វិចិត្រា** មន្ត្រីផ្នែកព័ត៌មានវិទ្យា

ផ្នែកគណនេយ្យ និងហិរញ្ញវត្ថុ

១១- លោក **កែម ចាន់ខឿន** ប្រធានផ្នែកគណនេយ្យនិងហិរញ្ញវត្ថុ

ផ្នែករដ្ឋបាល និងទំនាក់ទំនងសាធារណៈ

១២- លោក **ម៉ុត សទ្វារ** ប្រធានផ្នែករដ្ឋបាលនិងទំនាក់ទំនងសាធារណៈ

**ប្រការ២:** អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានបុគ្គលិក គ្រប់ប្រធាននាយកដ្ឋាន និង អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួង ព្រមទាំងសាមីខ្លួនដូចប្រការ ១ ខាងលើ ត្រូវអនុវត្តតាមប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

គាត ឈន់

**កន្លែងទទួល:**

- ធនាគារជាតិ នៃកម្ពុជា
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងធនធានទឹក និងឧតុនិយម
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ដូចប្រការ២
- ឯកសារ-កាលប្បវត្តិ